នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Mar-2011, 10:45
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: ចៅក្រមដោះស្រាយបណ្តឹងមិតចិត្ត (តាមរយៈអង្គជំនុំជម្រះសាលាដំបូង)

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០២ ខែ មិនា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា សុំប្តឹងជំទាស់ចៅក្រម

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
ព្រុំ ផល្លា
Göran SLUITER

Annebrecht VOSSENBERG
Alejandra CHAPA (កម្មសិក្សាការីច្បាប់)

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) និងមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (“សេចក្តីណែនាំអនុវត្ត”)[1] សហមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា (“ក្រុមមេធាវីការពារក្តី”) សូមដាក់ចម្លើយតបនេះចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង ធីរិទ្ធ អៀង សារី និង នួន ជា សុំប្តឹងជំទាស់ចៅក្រម (“ចម្លើយតប”)[2] ដែលបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១១[3] ។

## II. សំណើនៅក្នុងចម្លើយតប

### ក. ការវាយតម្លៃលើភាពអនាគតិនៅ អ.វ.ត.ក គឺជាការវាយតម្លៃមានលក្ខណៈទូលំទូលាយ

២. វិធាន ៣៤ -ដែលមិនបានលើកឡើងនៅក្នុងចម្លើយតបរួមរបស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងផ្នែកដែលមានចំណងជើងថា “ការវាយតម្លៃលើភាពអនាគតិ”- មិនបានកំណត់និយមន័យដូចអ្វីដែល កសព ចង់បាននោះទេ[4] ។ ថ្វីបើចម្លើយតបរួមបានលើកឡើងនូវបទដ្ឋានខុសៗគ្នាជាច្រើន[5] ក៏ចម្លើយតបរួមទទួលយកភាសាដែលមានន័យយ៉ាងច្បាស់របស់វិធាន ៣៤ ដែលថា “លក្ខខណ្ឌចាំបាច់ (*conditio sine qua non*) ក្នុងការបង្កើតកង្វះខាតនូវភាពអនាគតិ[6] នៅសាលាក្តីនេះ ជាសាមញ្ញទៅ “*គឺការពាក់ព័ន្ធណាមួយ*ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិត

---

[1] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៥ ។ អនុលោមតាមមាត្រ ៨.៤ “សំណើតបចំពោះចម្លើយតប នឹងត្រូវអនុញ្ញាតនៅក្នុងករណីតែមិនមានការស្នើសុំឱ្យមានការដេញដោលដោយផ្ទាល់មាត់ ហើយការឆ្លើយតបនោះត្រូវដាក់ក្នុងរយៈពេល០៥ (ប្រាំថ្ងៃ) នៃថ្ងៃប្រតិទិន គិតពីថ្ងៃជូនដំណឹង ជាភាសាដែលភាគីបានស្នើសុំ ដែលមានចែងនៅក្នុងមាត្រា ២.២ អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយតប ។

[2] ឯកសារ E-55 ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00647348–00647355 ។

[3] កត់សំគាល់: អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត ឯកសារនេះត្រូវបានដាក់ទាន់ពេលវេលា ។

[4] សូមមើលចម្លើយតបរួម នៅកថាខណ្ឌទី៣ (ពិភាក្សាការវាយយាតម្លៃលើភាពអនាគតិរបស់យុត្តាធិការដទៃជាច្រើន) ។

[5] ដូចខាងលើ ។

[6] ចម្លើយតបរួម នៅកថាខណ្ឌទី ៣ ។

ប្រាកដដល់អនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលំអៀង"[7]។ ផ្ទុយពីការលើកឡើងរបស់ កសព បទដ្ឋាននេះអាចក្តោបក្តាប់កំហុសឆ្គងយ៉ាងជាក់ស្តែងទាំងនៅក្នុង "ដំណើរការរបស់តុលាការ" ឬ "ផលរបស់តុលាការ"[8] ដែលជាទស្សនទានមិនចុះសម្រុងគ្នាទៅវិញទៅមក ដោយសារតែដំណើរការអាចជាសញ្ញាណនៃកំហុសឆ្គងយ៉ាងពិតប្រាកដនៅក្នុងលទ្ធផល។ អ្វីដែលសំខាន់នៅក្នុងករណីនេះ គឺថា*នៅក្នុងដំណើរការ*ចេញសាលក្រមប្រឆាំងនឹង ឌុច ("សាលក្រម ឌុច")[9] អង្គជំនុំជម្រះសាលាដំបូងបង្កើតនូវ*លទ្ធផល*ជាច្រើនដែលនឹងនាំឲ្យអ្នកសង្កេតការឥតលំអៀងដែលទទួលបានការជូនដំណឹងយ៉ាងសមហេតុផល[10] យល់ពីភាពលំអៀង ដោយផ្អែកលើការពាក់ព័ន្ធរបស់ចៅក្រមជាមួយសាលក្រម ឌុច ។

៣. ការលើកមកសំអាងនូវយុត្តិសាស្ត្រជាក់លាក់របស់តុលាការអឺរ៉ុបសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍[11] កសព លើកឡើងថា ការគ្មានភាពអនាគតិអាចយល់ឃើញយ៉ាងសមហេតុផលតែនៅពេលដែលបញ្ហាទាំងនោះ ត្រូវបានសម្រេចរួចមកហើយ "និយាយពីឧក្រិដ្ឋកម្មទាំងមូល"[12] និង "បំពេញតាមបទដ្ឋានស្តីពីភស្តុតាងដែលតម្រូវ ដើម្បីផ្តន្ទាទោសជនជាប់ចោទ"[13] ។ ខណៈដែលមេធាវីការពារក្តីទទួលស្គាល់ថាលក្ខណៈវិនិច្ឆ័យនេះបង្ហាញយ៉ាងច្បាស់ពីការលំអៀងរបស់តុលាការ ប៉ុន្តែ លក្ខណៈវិនិច្ឆ័យនេះមិនបង្កើតបានជាបញ្ជីពេញលេញនៃការបុរេវិនិច្ឆ័យដែលមិនអនុញ្ញាតចំពោះតុលាការឡើយ ទោះជាក្នុងមធ្យោ

---

[7] វិធាន ៣៤(៣) (បញ្ជាក់បន្ថែម) ។

[8] ចម្លើយតបរួម នៅកថាខណ្ឌទី៣ (សហព្រះរាជអាជ្ញាលើកឡើងថាភាពអនាគតិរបស់តុលាការមាននៅក្នុងដំណើរការ ហើយមិនជាប់ទាក់ទងនឹងលទ្ធផលទេ ។

[9] ឯកសារ E-188 " សាលក្រម" ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១០, ERN 00572517–00572797 (សាលក្រម ឌុច)។

[10] សូមមើលឯកសារ E54 "សំណើជាបន្ទាន់សុំប្តឹងជំទាស់ប្រឆាំងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១១ ERN 00641862–00641877 ("សំណើ") នៅកថាខណ្ឌទី១៥ ។

[11] សូមមើលចម្លើយតបរួម នៅកថាខណ្ឌទី៦ ។

[12] ចម្លើយតបរួម នៅកថាខណ្ឌទី៦ ។

[13] ចម្លើយតបរួម នៅកថាខណ្ឌទី៦ ។ សូមមើលផងដែរចម្លើយតបរួមនេះនៅកថាខណ្ឌទី១០ ("ដូច្នេះការថ្លែងទាំងនេះមិនមែនជាកម្មវត្ថុនៃបទដ្ឋានព្រហ្មទណ្ឌក្នុងការបង្ហាញភស្តុតាង "ឲ្យហួសពីវិមតិសង្ស័យ" ដូចបានឆ្លុះបញ្ចាំងនៅក្នុងភាសានៃឯកសារសម្រង់នៃបញ្ហានេះ ។

បាយណាក់ដោយ។ បទដ្ឋានក្នុងការគោរពតាមន័យទូលំទូលាយនៃវិធាន ៣៤ គឺការវាយតម្លៃរឿងក្តី *Karadzic* ដែលលើកសំអាងនៅក្នុងចម្លើយតបរួម: "ដើម្បីឱ្យសាលក្រម ឬសេចក្តីសម្រេចលើកមុន អាចបង្កើតឱ្យឃើញនូវភាពលំអៀង តាមរបៀបដែលមេធាវីការពារក្តីបានលើកជាទឡ្ហីករណ៍នោះ គឺភាពលំអៀងនោះចាំបាច់តោងតែ "[...] ដោយផ្ទាល់ ឬ*តាមការទាញសេចក្តីសន្និដ្ឋាន* បង្កើតបានជាការរកឃើញការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល [...] របស់ជនជាប់ចោទ"[14] ។ តាមរយៈខ្លឹមសាររបស់វា ការថ្លែងដែលពុំសូវហ្មត់ចត់នេះបង្ហាញពីការអស់លក្ខណៈសម្បត្តិ ផ្អែកលើការសម្រេចដោយមិនផ្ទាល់ ឬការសម្រេចនៅដំណាក់កាលដំបូង ដែលមិនចាំបាច់បង្កើតឱ្យដល់កម្រិតពិសេសណាមួយនៃភាពគ្រប់គ្រាន់របស់ភស្តុតាងឡើយ។ និយាយម្យ៉ាងទៀត វាឆ្លុះបញ្ចាំងយ៉ាងច្បាស់លាស់ពី scenario ដែលលើកឡើងនៅក្នុងបណ្តឹងជិតចិត្តរបស់មេធាវីការពារក្តី ។

៤. ឱកាសនានា "ដែលការលេចឡើងនៃភាពលំអៀងត្រូវបានរកឃើញ ដោយផ្អែកលើមូលដ្ឋាននៃការសម្រេចលើកមុន ជាពិសេសនៅក្នុងវិស័យនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ"[15] អាចជាឱកាសដ៏កម្រ ហើយ "កម្រិតនៃភាពត្រួតគ្នារវាងករណីនានា"[16] ពិតជាមិនអាចជៀសផុតបានឡើយ នៅតុលាការបណ្តោះអាសន្ន ព្រមទាំង (ប្រហែលជាពុំសូវកើត) នៅក្នុងតុលាការជាតិ ។ ប៉ុន្តែមេធាវីការពារក្តីមិនខ្វល់ខ្វាយច្រើនលើកំណត់ត្រាជាក់លាក់របស់តុលាការដទៃ ហើយក៏មិនរំខានដោយអត្ថិភាពត្រួតគ្នាខាងអង្គហេតុដែរ ។ អ្វីដែលសំខាន់ជាទីបំផុតនៅក្នុងករណីនេះ គឺការណ៍ដែលថាអង្គជំនុំជម្រះសាលាដំបូងនៅសាលាក្តីនេះ ហាក់ដូចជាបានទាញសន្និដ្ឋានផ្នែកច្បាប់យ៉ាងពិតប្រាកដ និងយ៉ាងរហ័ស ដែលប្រឆាំងនឹងជនជាប់ចោទ ។ ខណៈដែលចៅក្រមត្រូវបានតម្រូវឱ្យសម្រេចលើបញ្ហានានានៅក្នុងករណីផ្សេងៗគ្នា ដោយមានទឡ្ហីករណ៍ឈរលើ

---

[14] ចម្លើយតបរួម នៅកថាខណ្ឌទី៦ (លើកសំអាងរឿងក្តីរដ្ឋអាជ្ញា តទល់ *Karadzic* ករណីលេខ IT-95-05/18-PT, សេចក្តីសម្រេចដោយអង្គជំនុំជម្រះ តាមដីកាបង្គាប់របស់អនុប្រធានអង្គជំនុំជម្រះ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ នៅកថាខណ្ឌទី ២២ (បញ្ជាក់បន្ថែម) ។

[15] ចម្លើយតបរួម នៅកថាខណ្ឌទី១១ ។

[16] ចម្លើយតបរួម នៅកថាខណ្ឌទី១១ ។

កម្រងអង្គហេតុដូចៗគ្នា ឬស្រដៀងគ្នា[17] តែពួកគេត្រូវតែបានរារាំងមិនឲ្យធ្វើបុរេវិនិច្ឆ័យពីពិរុទ្ធភាព (ទាំងមូល ឬមួយផ្នែក) របស់បុគ្គលទាំងនោះដែលមិនទាន់នាំខ្លួននៅចំពោះមុខពួកគេនៅឡើយ ។

## ខ. មេធាវីការពារក្តីទទួលយកការវាយតម្លៃលើវិធាន ៣៤

៥. បន្ថែមពីលើការលាតត្រដាងភស្តុតាងពាក់ព័ន្ធទៅនឹង [...] ព្រឹត្តិការណ៍នៅក្នុងករណីទាំងពីរ[18] ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានបោះមួយជំហានបន្ថែម និងបានទាញសេចក្តីសន្និដ្ឋានផ្ទុយ ។ អាស្រ័យហេតុនេះ ផ្ទុយពីជំហាររបស់ កសព បញ្ហាគន្លឹះទាក់ទងនឹងពិរុទ្ធភាពរបស់ នួន ជា លែងបើកចំហរនៅក្នុងករណីទីពីរ តទៅទៀតហើយ[19] ។ តាមពិត បញ្ហានេះត្រូវបានបុរេវិនិច្ឆ័យដោយសាលក្រមទីមួយ រួចមកហើយ[20] ។ បើទោះបីពិរុទ្ធភាពទាំងមូលរបស់ នួន ជា មិនអាចសម្រេចបានក៏ដោយ[21] ក៏ការរកឃើញទាំងនេះកាលពីលើកមុន មិនអាចដកចេញ[22] (បដិសេធ) បានដែរ ហើយអ្នកសង្កេតការឥតលំអៀងដែលទទួលបានការជូនដំណឹងត្រឹមត្រូវ អាចសន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូង កង្វះខាតនូវភាពអនាគតិ ។

៦. កសព យល់ឃើញថា “កម្រងឯកសារមួយចំនួនដែលលើកសំអាងដោយមេធាវីការពារក្តី មិនមែនជាការសម្រេចរបស់តុលាការទៅតាមបញ្ហាពិតប្រាកដទាក់ទងនឹង នួន ជា ឬតួនាទីរបស់គាត់ឡើយ[23]” ប៉ុន្តែផ្ទុយទៅវិញ វាគ្រាន់តែជាការការអះអាងឡើងវិញម្តងទៀតនូវអ្វីដែល ឌុច

---

[17] ចម្លើយតបរួម នៅកថាខណ្ឌទី៤ ។

[18] ចម្លើយតបរួម នៅកថាខណ្ឌទី៤ (បានលើកមកសំអាងរឿងក្តីរដ្ឋអាជ្ញា តទល់ *Kordic និង Cerkez* សំណុំរឿង IT-95-14/2-PT, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំប្តឹងដិតចិត្តចៅក្រម Jorda និង Riad’, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៩៨ នៅទំព័រទី២) ។

[19] ចម្លើយតបរួម នៅកថាខណ្ឌទី៥ ។

[20] ដូចខាងលើ ។

[21] ដូចខាងលើ ។

[22] សូមមើលចម្លើយតប ជើងទំព័រ ២៤ (កត់សម្គាល់ថា ការរកឃើញបែបនេះ មិនត្រូវចងដោយ គោលការណ៍ *res judicata* ) សម្គាល់ ពាក់ព័ន្ធនឹងរឿងនេះ ជាការសំខាន់ណាស់ ដោយបញ្ជាក់បន្ថែមថា សាលក្រម ឌុច រួមទាំង ការយោងដល់ នួន ជា មានក្នុងឯកសារសាធារណៈ។

[23] ចម្លើយតប, កថាខណ្ឌទី៨។

ធ្លាប់បាននិយាយតែប៉ុណ្ណោះ ។ ប៉ុន្តែផ្នែកដ៏ទៃទៀតក្នុងសាលក្រម ឌុច គឺជា "អំណះអំណាងដែលមិនមានលក្ខណៈគ្រប់គ្រាន់[24]" យ៉ាងច្បាស់ក្រឡែតរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងមុខតំណែង និងតួនាទីរបស់ជនជាប់ចោទ[25]។ បញ្ហាទាំងពីរនេះ មិនអាចផ្តាច់ចេញពីគ្នាបានឡើយ ហើយបើពិនិត្យជារួមទៅ នឹងធ្វើឱ្យអ្នកសង្កេតការឥតលម្អៀងយល់ឃើញថាជនជាប់ចោទទទួលយកគោលជំហរដែលបង្កើតឡើងដោយ ឌុច ក្នុងការជំនុំជម្រះក្តីរបស់គាត់ជាជាង "ការលើកយកមកសំអាងដ៏ប្រុងប្រយ័ត្ននេះ [...] សម្រាប់មូលហេតុតែមួយគត់គឺដើម្បីផ្តល់ជូនអំពីប្រវត្តិសវតារដើមប៉ុណ្ណោះ [26]"។

៧. ទោះបីជាពុំមានការរកឃើញនូវបំណងឧក្រិដ្ឋទាក់ទងនឹង នួន ជា ក្នុងសាលក្រម ឌុច ក៏ដោយក៏វាមិនមែនមានន័យថាតុលាការនេះមានអនាគតិដែរ ។ ធាតុផ្សំសំខាន់ដែលទាក់ទងនឹងការទទួលខុសព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទ[27] ក្នុងសំណុំរឿង០០២ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចរួចមកហើយ ។ ករណី នួន ជា អាចមិនត្រូវបានដោះស្រាយទាំងស្រុងក្នុងសាលក្រម ឌុច [28] ប៉ុន្តែច្បាស់ណាស់ថាវាអាចប៉ះពាល់ដោយការសន្និដ្ឋានដែលមាននៅក្នុងសាលក្រមនោះ[29]។ ក្រៅពីការរកឃើញបឋមពីពិរុទ្ធរបស់ ឌុច [30] រាល់ការយោងទាំង

---

[24] សូមមើលចម្លើយតប, លេខសម្គាល់២៤ (ដោយកត់សម្គាល់ឃើញថាការរកឃើញបែបនេះ នឹងត្រូវចងជាប់កតាព្វកិច្ចអនុលោមតាមគោលការណ៍*អាជ្ញាអស់ជំនុំ*),កំណត់សម្គាល់៖ក្នុងបរិបទនេះ វាមានសារៈសំខាន់ណាស់ក្នុងការសង្កត់ធ្ងន់ថាសាលក្រម ឌុច រួមបញ្ចូលទាំងការយោងទាក់ទងនឹង នួន ជា ដែលមាននៅទីនេះ គឺជាឯកសារសាធារណៈ។

[25] សូមមើលសាលក្រម ឌុច, កថាខណ្ឌទី ៨៥, ៩៥។

[26] ចម្លើយតប, កថាខណ្ឌទី៨ (ដកស្រង់ករណី Karadzic, កថាខណ្ឌទី២២)

[27] ចម្លើយតប, កថាខណ្ឌទី៩។

[28] សូមមើលចម្លើយតប, កថាខណ្ឌទី៩ (Culpa ត្រូវបានដោះស្រាយទាក់ទងករណី ឌុច តែប៉ុណ្ណោះ មិនទាក់ទងនឹងករណីរបស់ជនជាប់ចោទឡើយ)។

[29] សូមមើលបណ្តឹងជិតចិត្ត, កថាខណ្ឌទី៣០ ដល់ ៣៣។

[30] សូមមើលចម្លើយតប, កថាខណ្ឌទី១០។ សេចក្តីយោងទាំងប៉ុន្មានអំពីតួនាទីរបស់ជនជាប់ចោទក្នុងករណី ឌុច គឺគ្រាន់តែដើម្បីគាំទ្រ និងជាថែដន្យ ចំពោះការរកឃើញសំខាន់ៗនៃពិរុទ្ធភាពរបស់ ឌុច ចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវបានគេចោទតែប៉ុណ្ណោះ។ *កំណត់សម្គាល់*៖មេធាវីការពារក្តីមិនដែលលើកឡើងថាសាល ក្រម ឌុច បានបង្កើតពិរុទ្ធភាព របស់ នួន ជា

អស់ទាក់ទងនឹង នួន ជា គួបផ្សំនឹងការរកឃើញដែលមានការជំទាស់ដទៃទៀតរបស់អង្គជំនុំជម្រះសាលាដំបូង[31] បានបំពេញបទដ្ឋានទូលំទូលាយរបស់វិធាន ៣៤ នៃវិធានផ្ទៃក្នុង។

៨. និយាយដោយខ្លីទៅ ករណីបច្ចុប្បន្ននេះ បង្ហាញពីករណីលើកលែងចំពោះបុគ្គលនានាដែលប្រឈមដោយតុលាការ EctHR ក្នុងរឿងក្តី *Ferrantelli* និង *Santangelo*[32] និង *Rojas-Morales*[33] ។ ដោយពិចារណាតិចតួចលើការយោងទាំងនេះ[34] ការរកឃើញផ្ទុយកាលពីលើកមុនរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង បានបង្ហាញថាពួកគេមិនអាចបំភ្លេចចោល[35] នូវទស្សនៈរបស់ពួកគេលើពិរុទ្ធភាពរបស់ជនជាប់ចោទ។ បើទោះបីសុទិដ្ឋិនិយមរបស់ កសព ក្នុងចំណុចនេះ[36] បានផ្តល់ឱកាសឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាជាថ្មីលើបញ្ហាដែលពាក់ព័ន្ធនេះ[37] ក៏វានឹងបង្កឲ្យមានគ្រោះថ្នាក់យ៉ាងធំធេង និងហានិភ័យដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក នួន ជា ដែរ ។

### គ.រចនាសម្ព័ន្ធរបស់ អវតក មិនអាចយកមកពិចារណានៅពេលសម្រេចលើពាក្យសុំជិតចិត្តនេះឡើយ

៩. បើពិនិត្យទៅលើការលើកមកសំអាងជាពិសេសរបស់ កសព នូវយុត្តិសាស្ត្រនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ <u>*មិនអចិន្ត្រៃយ៍*</u> ដែលមានអង្គជំនុំជម្រះច្រើន ចំណុចដែលបានលើកឡើងក្នុងបណ្តឹងជិតចិត្តនេះ មានការសង្កត់ធ្ងន់បន្ថែមទៀត។ នៅក្នុងការសម្រេចរបស់ខ្លួន ចៅក្រមដែលស្ថិតនៅក្នុងគណៈកម្មាធិការសម្រេចលើបណ្តឹងជិតចិត្ត មិនត្រូវទទួលឥទ្ធិពលមិនសម

---

ឡើយ។ ប៉ុន្តែដូចដែលបានកត់សម្គាល់ពីខាងលើ ករណីនេះ មិនត្រូវបានដាក់កំហិតយ៉ាងតឹងរឹងដោយវិធាន ៣៤ នៃវិធានផ្ទៃក្នុងឡើយ។

[31] សូមមើលបណ្តឹងជិតចិត្ត, កថាខណ្ឌទី៣ ដល់ ១០។

[32] សូមមើលបណ្តឹងជិតចិត្ត, កថាខណ្ឌទី៣០ ដល់៣៣។

[33] ដូចជើងទំព័រខាងលើ។

[34] ដូចជើងទំព័រខាងលើ។

[35] ចម្លើយតប, កថាខណ្ឌទី១២។

[36] សូមមើលចម្លើយតប, កថាខណ្ឌទី១២។

[37] ចម្លើយតប, កថាខណ្ឌទី១២។

ហេតុផល ពីការជ្រៀតជ្រែកជាក់ស្តែងដែលអាចចេញមកពីសេចក្តីសម្រេចផ្ទុយជាពិសេស ក្នុងករណីដែល អវតក ត្រូវបានរៀបចំ និងផ្តលថវិការក្នុងលក្ខណៈមួយដែលមានតែអង្គជំនុំជម្រះមួយតែប៉ុណ្ណោះ ។ ការដែលគ្មានចៅក្រមបន្ថែម (ឬក៏និយាយឲ្យទូទៅជាងនេះទៅទៀត ការខ្វះធនធានតុលាការ) គឺមិនមែនជាអំណះអំណាងដែលអាចទទួលយកបានសម្រាប់ការរំលោភសិទ្ធិដាច់ខាតរបស់លោក នួន ជា ក្នុងការទទួលការជំនុំជម្រះក្តីដោយចៅក្រមឥតលម្អៀងនោះទេ ទោះជាស្ថិតក្នុងករណីណាក៏ដោយ ។ ដូចដែល EctHR បានលើកឡើងថា៖ “រដ្ឋជាភាគី មានកាតព្វកិច្ចរៀបចំប្រព័ន្ធច្បាប់របស់ខ្លួនដើម្បីធានាការអនុវត្តស្របទៅនឹងលក្ខណ្ឌនៃមាត្រា ៦ (១) អនាគតិ គឺស្ថិតក្នុងចំណោមលក្ខណ្ឌទាំងនោះដោយគ្មានមន្ទិលសង្ស័យអ្វីទាំងអស់”[38]។ ដោយបន្ទរដល់ការរកឃើញនេះ មេធាវីការពារក្តីយល់ឃើញថា វចនាសម្ព័ន្ធ និង ឬក៏វចនាសម្ព័ន្ធផ្នែកហិរញ្ញវត្ថុរបស់ អវតក មិនអាចលើកយកមកពិចារណាឡើយ នៅពេលធ្វើសេចក្តីសម្រេចលើបណ្តឹងជិតចិត្តនេះ។

## III. សេចក្តីសន្និដ្ឋាន

១០. អាស្រ័យលើមូលហេតុដែលបានលើកឡើងក្នុងចម្លើយតបនេះ និងនៅក្នុងបណ្តឹងជិតចិត្ត មេធាវីការពារក្តី យល់ឃើញថាចំណុចសំខាន់ដែស្តែងឲ្យឃើញពីការលេចចេញនូវភាពលម្អៀងនេះ[39] ពិតជាត្រូវបានបំពេញ ដូច្នេះបណ្តឹងជិតចិត្តនេះ ត្រូវតែទទួលបានការអនុញ្ញាត។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

[38] សាលក្រមករណី Poppe, ECtHR 32271/04, *Poppe v The Netherlands*, ថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៩,កថាខណ្ឌទី ២៣។

[39] ចម្លើយតប, កថាខណ្ឌទី២។